គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៧ ចេញផ្សាយថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១
No. 7 Released on August 16, 2021

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## បរធនបាលកិច្ចបុគ្គល | Personal Trust



រូបភាព | Picture: https://cvtrustco.com/wp-content/uploads/2017/03/CVT-Business-Succession-MC-1200x550.jpg

បរធនបាលកិច្ចបុគ្គល គឺជាប្រភេទមួយក្នុងចំណោមប្រភេទបរធនបាលកិច្ច ៣ ប្រភេទផ្សេងទៀតរួមមាន បរធនបាលកិច្ចសាធារណៈ, បរធនបាលកិច្ចពាណិជ្ជកម្ម, និងបរធនបាលកិច្ចសង្គម។ បរធនបាលកិច្ចបុគ្គល ត្រូវបានបង្កើតឡើងដោយបរធនបាលទាយក ដើម្បីផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិទៅឱ្យបរធនបាលធ្វើការចាត់ចែង គ្រប់គ្រង និងថែរក្សាជំនួស សម្រាប់ជាប្រយោជន៍របស់បរធនបាលទាយកខ្លួនឯងវិញ ឬសម្រាប់បុគ្គលដែលបានកំណត់ជាក់លាក់ *(ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)*។ បរធនបាលកិច្ចបុគ្គលនេះ ត្រូវបានកំណត់លក្ខខណ្ឌ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ ដោយមានការព្រមព្រៀងរវាងបរធនបាលទាយក បរធនបាល និងអត្ថគាហកៈ តាមរយៈលិខិតបរធនបាលកិច្ច។

ការបង្កើតបរធនបាលកិច្ចបុគ្គល អាចធ្វើក្នុងលក្ខខណ្ឌដែល÷ (១)បរធនបាលទាយកជារូបវន្តបុគ្គល ដែលធ្វើប្រទានកម្មទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួន ឱ្យទៅបរធនបាល សម្រាប់ជាប្រយោជន៍របស់ខ្លួនផ្ទាល់ ឬរបស់បុគ្គលផ្សេងទៀត ឬ (២)ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិ ដោយបរធនបាលទាយកដែលនៅមានជីវិតហើយ ត្រូវធ្វើលិខិតបរធនបាលកិច្ចដោយមានការបញ្ជាក់ពីសារការី មេធាវី ឃុំសង្កាត់ ឬករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេលដែលបរធនបាលទាយកនោះទទួលមរណភាព ដែលតាមមតកសាសន៍នេះបង្កើតជាបរធនបាលកិច្ចស្របតាមក្រមរដ្ឋប្បវេណី។

បរធនបាលកិច្ចបុគ្គល ត្រូវទទួលបានការអនុញ្ញាតឱ្យបង្កើត និងចុះបញ្ជីនៅនិយ័តករបរធនបាលកិច្ច (ន. ប. ធ.)។

Personal Trust is one of other 3 trust categories such as Public Trust, Commercial Trust, and Social Trust. Personal Trust is created by trustor or trust creator for the interest of trustor/person specifically determined by trustor in order to transfer asset or fund to trustee to manage, administrate or safe keep instead of trustor *(Law on Trust, 2019)*. Personal trust legally binds the right, obligation and responsibility between trustor, trustee and beneficiary by trust instrument.

Personal trust is established in accordance with **(1)** trustor is a natural person who makes donation of his/her asset or fund to trustee for his/her interest or for other persons; or **(2)** transferring of asset or fund which made by the alive trustor. In this case, the trustor shall make the trust instrument with certifying from the notary, the lawyer or the commune; or in case the trustor is dead, trustor shall create through the will and testament which creates personal trust in line with civil code.

Personal Trust shall be granted approval to create and register from the Trust Regulator.

**អត្ថបទ៖ ឈាន សុខារី | Article: Sokhary Chhean**

**ឯកសារយោង | References**:

- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.